ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី
អង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល
លេខ: ១៣១/២៣ អអរ

## សេចក្តីប្រកាសព័ត៌មាន
## លទ្ធផលនៃសន្និសីទសារព័ត៌មានស្តីពី "ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តសៀមរាប"

នាព្រឹកថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣ អង្គភាពអ្នកនាំពាក្យរដ្ឋាភិបាលបានរៀបចំសន្និសីទសារព័ត៌មាន ស្តីពី **«ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក របស់រដ្ឋបាលខេត្តសៀមរាប»** ដែលមានវាគ្មិនចូលរួមគឺ៖

- **ឯកឧត្តម ទៀ សីហា អភិបាលនៃគណៈអភិបាលខេត្តសៀមរាប**
- **មន្ទីរអង្គភាពជំនាញជុំវិញរដ្ឋបាលខេត្តសៀមរាប**

ខ្លឹមសារនៃសន្និសីទសារព័ត៌មាន មានគោលបំណងពន្យល់ និងផ្សព្វផ្សាយដល់សាធារណជនឱ្យបានជ្រាបច្បាស់អំពី យន្តការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងភាពជោគជ័យដែលរដ្ឋបាលខេត្តសៀមរាប ខិតខំប្រឹងប្រែងអនុវត្ត ព្រមទាំងសម្រេចបានសមិទ្ធផលវិជ្ជមាន ក្រោមការដឹកនាំដ៏ប៉ិនប្រសប់ប្រកបដោយថាមពលរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។**

### I. ស្ថានភាពទូទៅ

ខេត្តសៀមរាប ចែកចេញជា ក្រុង១ ស្រុក១១ ឃុំ-សង្កាត់១០០ និង៩១០ភូមិ ដែលមានប្រជាពលរដ្ឋរស់នៅសរុបចំនួន ១.១៩១.៩៩៥នាក់ ស្មើនឹង ២៥៧.៦២៥គ្រួសារ។ សេដ្ឋកិច្ចខេត្តមានទំហំប្រមាណ ១.៧៣០,៩លានដុល្លារអាមេរិក ស្មើនឹង ៦,៤% នៃសេដ្ឋកិច្ចជាតិ ដែលចំណូលជាមធ្យមសម្រាប់មនុស្សម្នាក់ៗ ស្មើនឹង ១.៥១៧,៧ដុល្លារអាមេរិក។

## II. សមិទ្ធផលការងារ

ក្នុងរយៈពេល ៥ឆ្នាំកន្លងមកនេះ(២០១៨-២០២២) សមិទ្ធផលការងារសំខាន់ៗ ដែលសម្រេចបានរួមមានៈ

- **វិស័យគាំពារសង្គមៈ** រដ្ឋបាលខេត្ត បានអនុវត្តនូវគោលនយោបាយគាំពារសង្គរបស់រាជរដ្ឋាភិបាល ដោយបានឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះនានា រួមទាំងស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ សរុបជាទឹកប្រាក់ប្រមាណ ៣២៦.២៧៤លានរៀល ព្រមទាំងបានឧបត្ថម្ភជូនកម្មករនិយោជិតអំឡុងពេលមានវិបត្តិកូវីដ-១៩ ចំនួន១១៤.៩០៥នាក់ សរុបទឹកប្រាក់ប្រមាណ ៩,២លានដុល្លារអាមេរិក។
- **វិស័យទេសចរណ៍ៈ** ជាខេត្តដែលសម្បូរទៅដោយប្រាង្គប្រាសាទបុរាណ វប្បធម៌ ប្រវត្តិសាស្ត្រជាច្រើន ដែលជាសក្តានុពលអំណោយផលដល់វិស័យទេសចរណ៍ ដែលជាវិស័យសំខាន់ ក្នុងការលើកស្ទួយសេដ្ឋកិច្ចខេត្តទាំងមូល។ ក្នុងឆ្នាំ២០២២ មានភ្ញៀវទេសចរចំនួន ២ ៦៩២ ៤២៣នាក់ ក្នុងនោះភ្ញៀវអន្តរជាតិចំនួន ២៨៧ ៥៥៤នាក់។
- **វិស័យកសិកម្មៈ** ជាវិស័យដែលដើរទន្ទឹមគ្នានឹងវិស័យទេសចរណ៍ ក្នុងការទ្រទ្រង់ និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក៏ដូចជាសេដ្ឋកិច្ចជាតិទាំងមូល។ ប្រជាពលរដ្ឋប្រមាណជាង ៦៧% ប្រកបមុខរបរកសិកម្មនេះ ទៅលើផ្ទៃដីសរុប ២៩៦.៣០៧ហិកតា។ ខេត្តធានាបាននូវសន្តិសុខស្បៀងសម្រាប់ប្រើប្រាស់ ក៏ដូចជានាំចេញ ដោយផលស្រូវជាមធ្យមទទួលបានពី ៥៣៧ ទៅ៦០៨ពាន់តោនក្នុងមួយឆ្នាំ។ ក្រៅពីនេះ មានដំណាំសាកវប្បកម្ម បន្លែគ្រប់ប្រភេទ ពោត អំពៅ ដំឡូងមីជាដើម ដែលរួមចំណែកផ្គត់ផ្គង់តម្រូវការទីផ្សារ និងបង្កើនប្រាក់ចំណូលជូនប្រជាពលរដ្ឋ។
- **ការងារសន្តិសុខ សណ្តាប់ធ្នាប់ និងការផ្តល់សេវាសាធារណៈ៖** ខេត្តរក្សាបាននូវសន្តិសុខសណ្តាប់ធ្នាប់បានយ៉ាងល្អប្រសើរជូនប្រជាពលរដ្ឋ និងភ្ញៀវទេសចរណ៍ ដោយគណៈបញ្ជាការឯកភាពខេត្ត បានយកចិត្តទុកដាក់ខ្ពស់ក្នុងការការពារសណ្តាប់ធ្នាប់សាធារណៈ ដោយបានរៀបចំយុទ្ធនាការចុះអប់រំផ្សព្វផ្សាយ និងរៀបចំកងកម្លាំងប្រចាំការតាមតំបន់ ធ្វើឱ្យបទល្មើសគ្រប់ប្រភេទត្រូវបានបង្ការ និងបង្ក្រាបជាបន្តបន្ទាប់ នយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព បានអនុវត្តប្រកបដោយភាពជោគជ័យ ដោយ ៦៧ឃុំ-សង្កាត់ ទទួលបានចំណាត់ថ្នាក់លេខ១ ទទួលបានចំណាត់ថ្នាក់លេខ២ មាន២៤ឃុំ-សង្កាត់ និង៩ឃុំ-សង្កាត់ ទទួលបានចំណាត់ថ្នាក់លេខ៣ ក្នុងចលនាប្រលងប្រណាំង។ ជាមួយគ្នានេះ ការផ្តល់សេវាសាធារណៈ ក៏ទទួលបានការគាំទ្រ

ខ្ពស់ពីប្រជាពលរដ្ឋ តាមរយៈយន្តការច្រកចេញ-ចូលតែមួយ បានផ្តល់សេវាជូនប្រជាពលរដ្ឋលើ ១៤វិស័យ សរុបចំនួន ៧៦.១៩៦សេវា ទទួលបានចំណូល ២៤.៧៦៨លានរៀល។

- **ការងារអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធ៖** រដ្ឋបាលខេត្ត បានបន្តស្តារហេដ្ឋារចនាសម្ព័ន្ធទាំងនៅក្នុងទីក្រុង និងជនបទ ដោយផ្តោតសំខាន់ លើការសាងសង់ ជួសជុល ថែទាំងបណ្តាញផ្លូវថ្នល់នៅក្នុងទីក្រុង ពីទីប្រជុំជនទៅជនបទ និងទីជនបទ ដើម្បីចូលរួមចំណែកលើកស្ទួយជីវភាពប្រជាជន និងជំរុញកំណើនសេដ្ឋកិច្ចខេត្ត។ ជាមួយគ្នានេះ សោភណ្ឌភាពទីក្រុង ត្រូវបានយកចិត្តទុកដាក់ខ្ពស់ ដោយបានរៀបចំឱ្យមានប្រព័ន្ធលូរំដោះទឹកកខ្វក់ លូទឹកភ្លៀង រៀបចំចំណតសាធារណៈ ការបំពាក់កាមេរ៉ាសុវត្ថិភាព ភ្លើងសញ្ញាចរាចរណ៍ និងបំពាក់អំពូលបំភ្លឺតាមដងផ្លូវសាធារណៈផងដែរ។ ដោយឡែក ចំពោះការផ្គត់ផ្គង់អគ្គិសនីបានចែកចាយចំនួន ៩៨,៨១% និងបណ្តាញទឹកស្អាត ត្រូវបានគ្របដណ្តប់ ៧៦%។
- **ការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី៖** រដ្ឋបាលខេត្ត បានចុះបញ្ជីលក្ខណៈជាប្រព័ន្ធ និងចេញប័ណ្ណកម្មសិទ្ធជូនប្រជាពលរដ្ឋចំនួនសរុប ៤៨ ៤៧៦ប័ណ្ណ។ ក្រុមការងារខេត្ត បានចូលរួមជាមួយក្រុមការងារតម្រង់ទិស បានសម្របសម្រួលដោះស្រាយ ជាមួយប្រជាពលរដ្ឋដែលរស់នៅក្នុងតំបន់រមណីយដ្ឋានអង្គរ និងស្រង់ទិន្នន័យប្រជាពលរដ្ឋដែលស្ម័គ្រចិត្តផ្លាស់ប្តូរការរស់នៅពីតំបន់រមណីយដ្ឋានអង្គរ ទៅនៅតំបន់អភិវឌ្ឍន៍ធម្មជាតិរុនតាឯក និងតំបន់អភិវឌ្ឍន៍ពាក់ស្នែងសរុបចំនួន ៩.៦៩៥គ្រួសារ និងបានផ្តល់ប័ណ្ណក្រីក្រ ឧបត្ថម្ភគ្រឿងឧបភោគ បរិភោគ និងសម្ភារៈសំណង់ផងដែរ។

## III. ទិសដៅការងារបន្ត

រដ្ឋបាលខេត្ត បានដាក់ចេញនូវទិសដៅការងារសំខាន់ៗ រួមមាន៖

- បន្តពង្រឹងការអនុវត្តគោលនយោបាយ "ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព"
- បន្តសហការគ្នាឱ្យបានកាន់តែសកម្ម និងមានប្រសិទ្ធភាព ព្រមទាំងចាត់វិធានការបើកកិច្ចប្រតិបត្តិការបង្ការ បង្ក្រាបបទល្មើសគ្រប់ប្រភេទ
- អប់រំ ផ្សព្វផ្សាយ ពង្រឹងការទប់ស្កាត់ និងចាត់វិធានការតាមផ្លូវច្បាប់ចំពោះការបំផ្លាញធនធានធម្មជាតិ និងទន្ទ្រានកាន់កាប់ដីព្រៃឈើក្នុងតំបន់ការពារធម្មជាតិ ព្រៃសហគមន៍ ដែនអភិរក្ស និងរបៀងជីវៈចម្រុះ
- ពង្រឹងការផ្តល់សេវារដ្ឋបាលតាមរយៈច្រកចេញចូលតែមួយនៅថ្នាក់ខេត្ត ក្រុង ស្រុក ឱ្យបានឆាប់រហ័ស ធានាបានតម្លាភាព និងពន្លឿនការដោះស្រាយពាក្យបណ្តឹងនានារបស់ប្រជាពលរដ្ឋ

- ពង្រីកសក្តានុពលទេសចរណ៍ គុណភាពផលិតផល និងសេវាកម្មទេសចរណ៍ អភិវឌ្ឍធនធានមនុស្សផ្នែកជំនាញវិជ្ជាជីវៈទេសចរណ៍លើការងារបដិសណ្ឋារកិច្ច សេវាកម្មដឹកជញ្ជូន និងសេវាមគ្គុទ្ទេសក៍ទេសចរណ៍ ព្រមទាំងរៀបចំផែនការអភិវឌ្ឍទេសចណ៍ទៅតាមតំបន់គោលដៅទេសចរណ៍ក្នុងក្រុង និងតាមបណ្តាស្រុក
- ជំរុញការផ្សារភ្ជាប់រវាងវិស័យកសិកម្ម និងទេសចរណ៍ តាមរយៈពង្រឹងគុណភាពទិន្នផលកសិកម្ម និងយកទិន្នផលនោះ ទៅប្រើប្រាស់ក្នុងតម្រូវការទេសចរណ៍ ក្នុងន័យកាត់បន្ថយថ្លៃផលិត ទទួលបានប្រាក់ចំណេញខ្ពស់ លើកស្ទួយផលិតផលក្នុងស្រុក ជំរុញចលនាភូមិមួយ-ផលិតផលមួយ។

## IV. សម្គាល់

ដោយជាសមាជិកនៃទីក្រុងវៃឆ្លាតអាស៊ាន ក្រុងសៀមរាបបានអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដោយផ្តោតសំខាន់ទៅលើ ៤វិស័យដូចជា ទេសចរណ៍ឆ្លាតវៃ (Smart Tourism) ប្រព័ន្ធចល័តឆ្លាតវៃ (Smart Mobility) សន្តិសុខឆ្លាតវៃ (Smart Security) និងការគ្រប់គ្រងកាកសំណល់ឆ្លាតវៃ (Smart Waste Management) ដែលមានគម្រោងចំនួន៦ បានដាក់ឱ្យអនុវត្តសាកល្បងគឺ គម្រោងត្រួតពិនិត្យការចតយានយន្តខុសច្បាប់ គម្រោងកែលម្អការប្រមូលសំរាម គម្រោងបំប្លែងឯកសារឬព័ត៌មានទេសចរណ៍ឱ្យទៅជាទិន្នន័យឌីជីថល គម្រោងប្រព័ន្ធតាមដានលំហូរឯកសារផ្ទៃក្នុង គម្រោងតាមដានបរិស្ថានទីក្រុងដោយប្រើប្រាស់ Sensor និងគម្រោងកិច្ចសហការរវាងរដ្ឋ និងឯកជនក្នុងវិស័យទេសចរណ៍។ សូមគូសបញ្ជាក់ផងដែរថា ចំពោះការសាងសង់ព្រលានយន្តហោះសៀមរាប-អង្គរ ដែលស្ថិតនៅឃុំពពេល ស្រុកសូទ្រនិគម លើផ្ទៃដីប្រមាណ ៧៥០ហិកតា សម្រេចបានប្រមាណ ៧៥% ព្រមទាំងគ្រោងនឹងបញ្ចប់ការសាងសង់ និងដាក់ឱ្យដំណើរការនាខែតុលា ឆ្នាំ២០២៣ខាងមុខនេះផងដែរ៕

ថ្ងៃពុធ ៨កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២៣